ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ៨៧៦,៤២ ហិកតា នៅស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ក្នុងនោះ កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ និងធ្វើអនុយោគជាដីឯកជនរបស់រដ្ឋ និងកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន Great Field សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២០៦ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៣/២០៧ ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១៣
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ០៨៧ អបខ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ២០១៣របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ដីសរុបទំហំ ៨៧៦,៤២ ហិកតា ក្នុងនោះ (១) ទំហំ ៧៤៣,២៣ ហិកតា កាត់ចេញពីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៣១៣/២០៧ ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១៣ និងធ្វើអនុយោគជាដីឯកជនរបស់រដ្ឋ និង(២) ទំហំ ១៣៣,១៩ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន Great Field សម្រាប់ធ្វើប្រទានកម្មទំហំ ៦៦៤,៦៩ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ២១១,៧៣ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិគ្រៀលពង ឃុំតាសាល ស្រុកឱរ៉ាល់ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ២០៦ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិគ្រៀលពង ឃុំតាសាល ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ។

**មាត្រា ៣..**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤..**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មិនា ឆ្នាំ២០១៣

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៥*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ...៧៨...អនក្រ.បក.................................ចុះថ្ងៃទី..០៤...ខែ..មីនា..ឆ្នាំ២០១៣ ស្តីពីការកាត់ឆ្វៀលដីសរុបទំហំ ៨៧៦,៤២ ហិកតា ចេញពីផែនទីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ដែលក្នុងនោះត្រូវបានធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ឆ្វៀលដីទំហំ ៦៦៤,៦៩ ហិកតា ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងរស់នៅជាក់ស្តែងចំនួន ២០៦ គ្រួសារ និងរក្សាទុកជាដីសាធារណៈរបស់រដ្ឋ ទំហំ ២១១,៧៣ ហិកតា នៅភូមិក្បៀលកាច ឃុំតាសាល ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ




តារាងចំណុចនិយាមការ

| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| 1 | 382042 | 1295653 | 44 | 380414 | 1294205 |
| 2 | 382006 | 1295664 | 45 | 380377 | 1293954 |
| 3 | 381485 | 1295464 | 46 | 380227 | 1293943 |
| 4 | 381610 | 1295366 | 47 | 379914 | 1293567 |
| 5 | 381704 | 1295327 | 48 | 379717 | 1293760 |
| 6 | 381641 | 1295305 | 49 | 379358 | 1293936 |
| 7 | 381497 | 1295264 | 50 | 379074 | 1293466 |
| 8 | 381438 | 1295283 | 51 | 379646 | 1293040 |
| 9 | 381389 | 1295350 | 52 | 379070 | 1292065 |
| 10 | 381376 | 1295422 | 53 | 378780 | 1292467 |
| 11 | 381182 | 1295348 | 54 | 378489 | 1292316 |
| 12 | 381214 | 1294793 | 55 | 378710 | 1291963 |
| 13 | 380826 | 1295012 | 56 | 378548 | 1291758 |
| 14 | 380149 | 1295013 | 57 | 378863 | 1291369 |
| 15 | 379934 | 1294917 | 58 | 379917 | 1292496 |
| 16 | 379812 | 1295028 | 59 | 380087 | 1292268 |
| 17 | 378967 | 1295446 | 60 | 380147 | 1292023 |
| 18 | 378433 | 1295624 | 61 | 379977 | 1291762 |
| 19 | 378381 | 1295391 | 62 | 380483 | 1291520 |
| 20 | 378407 | 1295184 | 63 | 380723 | 1291423 |
| 21 | 378566 | 1295180 | 64 | 380719 | 1291527 |
| 22 | 378682 | 1295325 | 65 | 380586 | 1291832 |
| 23 | 378978 | 1295139 | 66 | 380217 | 1292041 |
| 24 | 379006 | 1295236 | 67 | 380550 | 1292284 |
| 25 | 379194 | 1295015 | 68 | 381110 | 1292061 |
| 26 | 379330 | 1294976 | 69 | 381106 | 1291936 |
| 27 | 379283 | 1294822 | 70 | 380866 | 1291889 |
| 28 | 379359 | 1294805 | 71 | 380862 | 1291845 |
| 29 | 379379 | 1295001 | 72 | 380971 | 1291793 |
| 30 | 379506 | 1294929 | 73 | 381183 | 1291771 |
| 31 | 379494 | 1294864 | 74 | 382294 | 1291957 |
| 32 | 379646 | 1294677 | 75 | 382274 | 1292197 |
| 33 | 379726 | 1294608 | 76 | 382141 | 1292316 |
| 34 | 379660 | 1294478 | 77 | 382039 | 1292629 |
| 35 | 379433 | 1294526 | 78 | 382110 | 1292901 |
| 36 | 379250 | 1294559 | 79 | 381935 | 1292996 |
| 37 | 379070 | 1294860 | 80 | 382066 | 1293090 |
| 38 | 378884 | 1294899 | 81 | 381966 | 1293349 |
| 39 | 378736 | 1294461 | 82 | 382094 | 1293687 |
| 40 | 379262 | 1294510 | 83 | 381983 | 1294089 |
| 4 | 379899 | 1294113 | 84 | 381724 | 1294426 |
| 42 | 380147 | 1294173 | 85 | 381722 | 1294674 |
| 43 | 380206 | 1294376 | 86 | 381985 | 1295161 |

សញ្ញាសំគាល់

- ភូមិ
- សាលាឃុំ
- សាលាស្រុក
- ស្ទឹង/អូរ មានទឹកជាប្រចាំ
- ស្ទឹង/អូរ មានទឹកតែរដូវវស្សា
- ផ្លូវជាតិលេខមួយខ្ទង់
- ផ្លូវក្រួសក្រហម ឬ ក្រាលកៅស៊ូ
- ផ្លូវរទេះ ឬ ផ្លូវដើរ
- ព្រំប្រទល់រាជធានី-ខេត្ត
- ព្រំប្រទល់ក្រុង-ស្រុក-ខណ្ឌ
- ព្រំប្រទល់ឃុំ-សង្កាត់
- ព្រំដីស្នើសុំកាត់ចេញពីផែនទីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់

គម្របព្រៃឈើឆ្នាំ២០០២

- ដីព្រៃពាក់កណ្តាលស្រោង
- ដីព្រៃល្បោះ
- ពិតានព្រៃ

មាត្រដ្ឋាន 1:20,000

0 500 1,000
Meters
Coordinate System: UTM, Zone: 48N
Horizontal Datum: WGS_84 Grid: 1000m

ផែនទីស្រុកឱរ៉ាល់

